# <u>សន្និបាតបញ្ញវន្តពិភពលោកលើកទី៣ ទាក់ទាញចំណាប់អារម្មណ៍ពីសំណាក់ឥស្សរជន កំពូលៗរបស់ជាតិ</u>

គណៈប្រតិភូចំនួន៥០០រូប នឹងអញ្ជើញចូលរួមក្នុងសន្និបាតបញ្ញវន្តពិភពលោកលើកទី៣ (GAC) នៅថ្ងៃទី១៧–១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសណ្ឋាគារ សុខា ភ្នំពេញ។ ព្រឹត្តិការណ៍នេះរៀបចំឡើងដោយ IDP Education ដែលជាស្ថាប័នផ្តល់សេវាកម្មផ្នែកការអប់រំអន្តរជាតិធំជាងគេនៅក្នុងពិភពលោក ហើយបានរៀបចំធ្វើជាម្ចាស់ផ្ទះស្វាគមន៍វាគ្មិនជាជនជាតិខ្មែរ និងអន្តរជាតិជាច្រើនរូប។

សន្និបាតប្រចាំឆ្នាំនេះ បានប្រមូលផ្តុំនិស្សិតបញ្ញវន្តដែលបានបញ្ចប់ការសិក្សានៅក្នុងប្រទេស និងមកពីប្រទេសអូស្ត្រាលី កាណាដា ណូវែលហ្សេឡង់ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក បារាំង រុស្ស៊ី កូរ៉េ ជប៉ុន ចិន ម៉ាឡេស៊ី សិង្ហបូរី និងប្រទេសផ្សេងៗទៀត ដែលបង្កើតជាវេទិកាជួបជុំគ្នាមួយដើម្បីចែករំលែកគំនិត និងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកជំនាញ អ្នកដែលមានតួនាទីក្នុងការសម្រេចចិត្ត និងថ្នាក់ដឹកនាំនៅក្នុងរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ សន្និបាតបញ្ញវន្តពិភពលោក ឆ្នាំ២០១៧នេះត្រូវបានដាក់បញ្ចូលគ្នានូវ បីផ្នែកធំៗរួមមាន Global Business and Education Forum, Global Education and Career Expo និង Global Alumni Reunion Gala Dinner.

ក្នុងចំណោមវាគ្មិនជាតិ និងអន្តរជាតិសំខាន់ៗដទៃទៀតក៏មានការចូលរួមជាវាគ្មិនកិត្តយសពីសំណាក់ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

លោកជំទាវ **Angela Corcoran** ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជាមានប្រសាសន៍ថា "យើងមានមោទនភាពចំពោះទំនាក់ទំនងខ្លាំងរវាងប្រទេសអូស្ត្រាលីនិងកម្ពុជាក្នុងវិស័យអប់រំ។ ជាក់ស្តែង IDP Education កំពុងប្រារព្ធខួបទី ២៥ ឆ្នាំរបស់ខ្លួន។ ចាប់តាំងពីឆ្នាំ ១៩៩២ មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការអប់រំ របស់ IDP បានជួយប្រជាជនកម្ពុជារាប់មុ◌ឺននាក់ឱ្យបង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេ រួមទាំងនិស្សិតជាច្រើនដែលបានបន្តការសិក្សានៅប្រទេសអូស្ត្រាលី។

ឯ.ឧ **Bill Longhurst** ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជាមានប្រសាសន៍ថា "ខ្ញុំជឿជាក់ថា កម្មវិធីសន្និបាតបញ្ញវន្តពិភពលោក នឹងរៀបចំការពិភាក្សានៃគំនិតផ្តួចផ្តើមដ៏អស្ចារ្យស្រដៀងគ្នាជាច្រើននៅក្នុងវិស័យអប់រំ។ ខ្ញុំសូមជូនពរដល់កម្មវិធី និងអ្នកចូលរួមទាំងអស់ជោគជ័យ ក្នុងការរៀនសូត្រ ការទំនាក់ទំនងគ្នា និងការចែករំលែកបទពិសោធន៍។

ឯ.ឧ **George Edgar** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជាមានប្រសាសន៍ថា "សន្និបាតបញ្ញវន្តពិភពលោកជាឱកាសដ៏ល្អសម្រាប់សមាជិកនៃសមាគមអតីតនិស្សិតមកពីប្រទេសផ្សេងៗ ដើម្បីមកចូលរួមចែករំលែកបទពិសោធន៍ និងព័ត៌មាន ហើយបង្កើតការទំនាក់ទំនងជាមួយ អតីតនិស្សិតបញ្ចប់ការសិក្សាពីជុំវិញពិភពលោក។

សន្និបាតមានការរៀបចំជាអង្គវេទិកាជជែកពិភាក្សា ព្រមជាមួយនឹងសំណួរចម្លើយលើប្រធានបទនានាដែលផ្តោតជាសំខាន់លើបញ្ហាដែលទាក់ទងនឹងប្រទេសកម្ពុជា។ ប្រធានបទនឹងគ្របដណ្តប់លើបញ្ហាពាក់ព័ន្ធលើគ្រប់វិស័យជាមួយអ្នកតំណាង ដែលចូលរួមក្នុងការពិភាក្សានេះ។ ប្រធានបទមានដូចជា៖

The Future of Agribusiness; Business Communication in the Digital Age; Domestic v international Business: Profit and Pitfalls; Attraction and Retention: Is there more to life than money?; Innovation-Driven Leadership; Cambodia’s Rising Stars; Trendsetters: The race for emerging consumer markets;

Why is CSR good for business?; Rise of creative industries; Rise of intra-regional travel; Cambodia Property: Boom or Bust?; and Labour Mobility: Blessing or Curse?

លោក ម៉ៅស្រេង នាយក IDP Education ប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា "សន្និបាតបញ្ញវន្តពិភពលោក ផ្តល់ឱកាសពិសេសមួយសម្រាប់អតីតនិស្សិតជួបជុំគ្នា ចែករំលែកនូវបទពិសោធន៍នានា និងប្រើប្រាស់នូវសក្តានុពលចំណេះដឹងរបស់ពួកគេជាមួយថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាលក្នុង វិស័យឧស្សាហកម្ម និងសង្គមស៊ីវិល។" គាត់បានបន្ថែមទៀតថា៖ "សន្និបាតបញ្ញវន្តពិភពលោក ឆ្លុះបញ្ចាំងឱ្យឃើញពីឥទ្ធិពលដ៏សំខាន់ដែលអតីតនិស្សិតមានចំពោះការអភិវឌ្ឍន៍ធនធានមនុស្សរបស់ជាតិ និងការស្តែងឱ្យឃើញនូវធនធានមនុស្សទាំងនោះ នៅកម្រិតខ្ពស់បំផុតក្នុងជួររដ្ឋាភិបាល និងក្នុងវិស័យនានា។"

ឯ.ឧ Hidehisa Horinouchi ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាមានប្រសាសន៍ថា "សន្និបាតបញ្ញវន្តពិភពលោក ជាឱកាសដ៏អស្ចារ្យសម្រាប់អតីតនិស្សិតកម្ពុជាដែលមានភាពសកម្មនៅក្នុងវិស័យផ្សេងៗរបស់ពួកគេហើយកំពុងប្រើប្រាស់បទពិសោធន៍របស់ពួកគេនៅទូទាំងពិភពលោកដើម្បីចែករំលែកចំណេះដឹង និងជំនាញរបស់ពួកគេជាមួយគ្នា។ លើសពីនេះកិច្ចពិភាក្សាដែលបានធ្វើឡើងនៅមហាសន្និបាតនេះជារឿយៗឆ្លុះបញ្ចាំងពីទស្សនៈសកលលោកនិងនាំមកនូវគំនិតថ្មីជាច្រើនដល់ប្រទេសកម្ពុជា។ ជាពិសេសនៅឆ្នាំនេះសន្និបាតនេះ នឹងត្រូវ ធ្វើឡើងរយៈពេលពីរថ្ងៃពេញ ហើយខ្ញុំជឿជាក់ថាអ្នកចូលរួមនឹងឆ្លៀតយកប្រយោជន៍ពីកម្មវិធីនេះ ហើយនឹងចំណាយពេលវេលាដ៏មានតម្លៃដើម្បីចែករំលែកបទពិសោធន៍ និងសកម្មភាពរបស់ពួកគេ ជាមួយអ្នកចូលរួមផ្សេងៗទៀត។"

GAC2017 បានទាក់ទាញអ្នកឧបត្ថម្ភ និងអ្នកគាំទ្រជាច្រើនមកពីបណ្តាក្រុមហ៊ុន សភាពាណិជ្ជកម្ម សមាគមអតីតនិស្សិត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។ GAC2017 សូមថ្លែងអំណរគុណចំពោះ៖

- AIA (Cambodia) Life Insurance Plc. and IELTS as Platinum Sponsors;
- Australian Centre of Education (ACE) as Gold Sponsor; and
- The British Embassy, CPA Australia, ATHE Cambodia, Singapore Cambodia International Academy (SCIA) and Australian Migration Agents (AMA) as Silver Sponsors.

លោក **Bretton G. Sciaroni** ប្រធានសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជាមានប្រសាសន៍ថា"សភាពាណិជ្ជកម្មអន្តរជាតិនៃប្រទេសកម្ពុជាមានសេចក្តីរីករាយក្នុងការគាំទ្រសន្និបាតបញ្ញវន្តពិភពលោកលើកទី៣ ដែល IDP រៀបចំនេះ។ ខ្ញុំបានចូលរួមនៅក្នុងកម្មវិធីនេះពីមុន ហើយបានឃើញផលវិជ្ជមានរបស់ការអប់រំខ្ពស់ទៅលើ សហគមន៍អាជីវកម្មនៅកម្ពុជា។ យើងរីករាយដែលឃើញ IDP បន្តបង្កើនទំហំនៃវេទិកាពាណិជ្ជកម្ម ដោយការរួមបញ្ចូលការអប់រំ និងអាជីពសម្រាប់លទ្ធផលនាពេលអនាគត។"

ពិព័រណ៌ការសិក្សានៅបរទេស និងការងារ ដែលនឹងដំណើរការស្របគ្នាទៅនឹងសកម្មភាពដទៃទៀតរបស់ GAC ដោយមានការចូលរួមពីស្ថាប័នអប់រំក្នុងស្រុក និងអន្តរជាតិដែលនឹងផ្តល់ព័ត៌មានអំពីអាហារូបករណ៍ និងឱកាសសិក្សានៅបរទេស ព្រមទាំងក្រុមហ៊ុនកំពុងស្វែងរកបុគ្គលិក។ និស្សិត ឪពុកម្តាយ និងសាធារណជន ជាង ៣ ពាន់នាក់ នឹងចូលរួមពិព័រណ៌ពិព័រណ៌ការសិក្សានៅបរទេស និងការងារនេះដោយឥតគិតថ្លៃ។

លោក ឈាង វ៉ាន់តាក់ ប្រធានភ្នាក់ងារបញ្ជូនសិស្សទៅសិក្សានៅបរទេស នៃ IDP Education មានប្រសាសន៍ថា "ពិព័រណ៌ការសិក្សានៅបរទេស និងការងារនឹងអនុញ្ញាតឱ្យសិស្ស និស្សិតស្វែងយល់ពីការសិក្សាកម្រិតពិភពលោកដោយពិភាក្សាជាមួយស្ថាប័នអន្តរជាតិផ្សេងៗ និងដើម្បីជួយពួកគេពិចារណាពីមុខវិជ្ជាដែលការគួរសិក្សានៅបរទេស។ យើងមានក្តីរំភើបរីករាយក្នុងការស្វាគមន៍សាលារៀន និងសាកលវិទ្យាល័យនានាមកពីប្រទេសកម្ពុជា សិង្ហបុរី អូស្ត្រាលី នូវែលហ្សេឡង់ ចក្រភពអង់គ្លេស កាណាដា និងសហរដ្ឋអាមេរិកនៅព្រឹត្តិការណ៍នេះ។"

ក្រៅពីនេះ ពិព័រណ៍ការសិក្សានៅបរទេស និងការងារ ក៏នឹងរួមបញ្ចូលឱកាសពិភាក្សារវាងតំណាងនិយោជិត និង បុគ្គលិក រួមជាមួយសំណួរ ចម្លើយ។

GAC2017 នឹងបញ្ចប់ជាមួយ Gala Dinner ដ៏រីករាយដែលលាយបញ្ចូលគ្នាជាមួយបរិយាកាសក្នុងការអបអរសាទរ ខួប ២៥ ឆ្នាំរបស់ IDP Education នៃប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

សម្រាប់ការចុះឈ្មោះចូលរួម សូមចូលទៅកាន់៖ www.cambodiaga.org

---




---

For further information or to support GAC2017, please contact:

**Trina CAPPS [EN]**
GAC Event Coordinator
IDP Education (Cambodia)
Tel: +855 23 222 325
E-mail: trina.capps@idp.com

**CHEA Chendamony [KH]**
Client Service Manager
IDP Education (Cambodia)
Tel: +855 23 222 325
Email: chendamony.chea@idp.com

Website: www.cambodiaGA.org
Facebook: https://www.facebook.com/cambodiaga/
LinkedIn: https://www.linkedin.com/in/cambodiaga/